## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
លេខ ៤៧៥-៩៦ សរណ

# ប្រធានតុលាការកំពូល

**ជម្រាបមក**

លោកប្រធានតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីចំណាត់ការប្រគល់លិខិតផ្សេងៗ និងដីកាកោះរបស់តុលាការកំពូល ។

ខ្ញុំសូមជម្រាបលោកថាតុលាការកំពូលបានកត់សម្គាល់ឃើញថាតុលាការគ្រប់ខេត្តក្រុងបានយកចិត្តទុកដាក់ច្រើនហើយ ប៉ុន្តែនៅមានការយឺតយ៉ាវ ក្នុងការប្រគល់លិខិតផ្សេងៗ និងដីកាកោឱ្យដល់សាមីខ្លួនពិសេសគឺការបង្វិលដើមលិខិតមកតុលាការកំពូលពុំបានមុខថ្ងៃណត់ ។ ដូច្នេះដើម្បីពង្រឹងការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ តុលាការកំពូលសុំឱ្យលោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង ខិតខំយកចិត្តទុកដាក់ចាត់ការឱ្យប្រគល់លិខិតផ្សេងៗ និងដីកាកោះឱ្យដល់សាមីខ្លួន រួចបង្វិលដើមលិខិត និងដើមដីកាមកតុលាការកំពូលវិញឱ្យបានមុនថ្ងៃកំណត់ ។

តុលាការកំពូលសង្ឃឹមថា អស់លោកច្បាស់ជាយកចិត្តទុកដាក់ជួយបំពេញភារកិច្ចនេះឱ្យបានត្រឹមត្រូវនិងយ៉ាងឆាប់រហ័ស តាមសំណូមពរនេះជាពុំខាន ។

**សូមជូនពរ សុខភាពល្អ និងជ័យជំនះ**

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៦

ចម្លងជូន
-ក្រសួងយុត្តិធម៌
-ដើម្បីជូនជ្រាប

**ចាន់ សុក**